# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## អាជ្ញាធរទន្លេសាប

# ផែនការសកម្មភាពការងារ
# អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប
# (២០១៤-២០១៦)

# មាតិកា

ទំព័រ

**១. សេចក្តី**......................................................................1

១.១. ការយល់ដឹងពីបឹងទន្លេសាប......................................................................1

១.២. ការយល់ដឹងពីអាជ្ញាធរទន្លេសាប......................................................................3

**២. ស្ថានភាពអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប**......................................................................4

២.១. រចនាសម្ព័ន្ធគ្រប់គ្រងអាជ្ញាធរទន្លេសាប......................................................................5

២.២. នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ......................................................................6

២.៣. នាយកដ្ឋានធនធានធម្មជាតិ......................................................................6

២.៤. នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស......................................................................6

២.៥. នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ......................................................................7

**៣. គោលបំណងនៃផែនការសកម្មភាពការងារ**......................................................................7

**៤. លទ្ធផល** (Outcome) **នៃផែនការសកម្មភាពការងារ**......................................................................7

**៥. ធាតុចេញ** (Output) **នៃផែនការសកម្មភាពការងារ**......................................................................7

**៦. សកម្មភាពប្រគបត្តការងារ**......................................................................8

**៧. តាមដានត្រួតពិនិត្យ និងវាយតំលៃ**......................................................................15

**៨. តារាងម៉ាទ្រីសសកម្មភាពប្រតិបត្តការងារ**......................................................................19

**៩. ថវិកាផែនការសកម្មភាពការងារ**......................................................................32

## ១. សាវតា

ឯកសារផែនការសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាបត្រូវបានរៀបចំឡើង ដោយមានការចូលរួមពីបណ្តានាយកដ្ឋាន ស្ថិតក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដោយបង្ហាញពី សកម្មភាពអនុវត្តការងារប្រចាំឆ្នាំរបស់នាយកដ្ឋាន ក្នុងការលើកកម្ពស់ប្រសិទ្ធភាពការងារ របស់អាជ្ញាធរទន្លេសាប ឲ្យសម្រេចបានជោគជ័យ ប្រកបដោយចិរភាពក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ។

## ១.១. ការយល់ដឹងពីបឹងទន្លេសាប

បឹងទន្លេសាប គឺជាបឹងទឹកសាបដ៏ធំជាងគេនៅតំបន់អាស៊ីអាគ្នេយ៍ ។ បឹងនេះមានបណ្តោយប្រមាណ ១១៦ គ.ម ទទឹងប្រមាណពី ៣ គ.ម ទៅ ៣៣ គ.ម និងមានឆ្នេរប្រវែងប្រមាណ ៤៨២ គ.ម នៅរដូវប្រាំង ។ បឹងទន្លេសាប ជាបេះដូងនៃប្រទេសកម្ពុជាដែលមានតម្លៃមិនអាចកាត់ថ្លៃបានលើផ្នែកសង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន ។ ក្នុងមួយឆ្នាំៗបឹងទន្លេសាបបានស្រូបយកទឹកជំនន់ពីទន្លេមេគង្គប្រមាណជា ២០% ។ វិសាលភាព របស់បឹងទន្លេសាបមានការប្រែប្រួលទៅតាមរដូវកាល ។ នៅរដូវប្រាំងពេលដែលទឹកបឹងមានជម្រៅពី ១ ម៉ែត្រ ទៅ ២ ម៉ែត្រ បឹងទន្លេសាបមានផ្ទៃក្រឡាប្រមាណ ២៥០.០០០ ហិកតា ប៉ុន្តែនារដូវវស្សា ពេលដែលទឹកបឹង មានជម្រៅពី ៨ ទៅ ១១ ម៉ែត្រ នោះបឹងទន្លេសាបមានផ្ទៃក្រឡាប្រមាណ ១.៥០០.០០០ ហិកតា ។ មាឌទឹកបឹងទន្លេសាបនៅរដូវវស្សាបានមកពីទន្លេមេគង្គ ៦២% និង ៣៨% ទៀតបានមកពីបណ្តាស្ទឹងធំៗ ដែលនៅជុំវិញ ចំនួន ១១ ។ មាឌទឹកបឹងទន្លេសាបប្រែប្រួលប្រមាណពី ៤.៥០០ លានម៉ែត្រគូប នៅរដូវប្រាំង ទៅ ១៣៥.០០០ លានម៉ែត្រគូបនៅរដូវវស្សា ។ ផ្ទៃក្រឡាបឹងទន្លេសាបនៅរដូវវស្សាមានទំហំធំជាងរដូវប្រាំង ប្រមាណពី ៥ ទៅ ៦ ដង ។

ដូចដែលបានលើកឡើងពីខាងដើមរួចមកហើយថា បឹងទន្លេសាបជាអាយុជីវិតរបស់ប្រទេសកម្ពុជា ព្រោះ បឹងទន្លេសាបជាតំបន់ទំនាបដ៏ធំល្វឹងល្វើយនៅចំកណ្តាលប្រទេសកម្ពុជា ។ ក្រៅពីការទទួលទឹកជំនន់ទន្លេមេគង្គ បឹងនេះបានស្រូបយកទឹកពីតំបន់ខ្ពង់រាបនានាដែលស្ថិតនៅជុំវិញ ។ ពេលទឹកហូរធ្លាក់មកកាន់បឹងទន្លេសាប ប្រាកដណាស់គឺហូរនាំទាំងដី ទាំងល្បាប់ ទៅចាក់បំពេញបឹងទន្លេសាប ដែលកត្តានេះអាចធ្វើឱ្យបឹងដ៏ធំនេះងាយគោករាក់ជាទីបំផុត ប៉ុន្តែអ្វីដែលជាលក្ខណៈពិសេសនោះគឺព្រៃលិចទឹកនៅជុំវិញបឹងនេះឯងដែលបានដើរតួនាទីជា តម្រងត្រងច្រោះយកដី និងល្បាប់នោះមួយភាគធំមិនឱ្យហូរធ្លាក់ចូលក្នុងបឹងទន្លេសាបនោះទេ ។ ដូចនេះបើព្រៃលិចទឹកត្រូវបានបំផ្លាញអស់ តើក្នុងមួយឆ្នាំៗមានដី និងល្បាប់ប៉ុន្មានហូរចូលទៅបឹងទន្លេសាប ? ចុះបើបឹងទន្លេសាប គោករាក់ តើមាឌទឹកបឹងទន្លេសាបប្រមាណ ១៣៥.០០០ លានម៉ែត្រគូប នៅរដូវវស្សានោះ យកទៅទុកនៅឯណា ? តើពេលនោះប្រទេសកម្ពុជា នឹងមានស្ថានភាពដូចម្តេច ?

ការស្រូបយកទឹកពីទន្លេមេគង្គនារដូវវស្សា និងការបញ្ចេញទឹកទៅឱ្យទន្លេមេគង្គវិញនារដូវប្រាំងបានក្លាយទៅជាបាតុភូតជលសាស្ត្រធម្មជាតិមួយដែលគេកម្រនឹងបានជួបប្រទះ ។ បាតុភូតនេះបានបង្កើតឡើងនូវតំបន់ដីសើម និង ព្រៃលិចទឹកដ៏ធំល្វឹងល្វើយ ដែលផ្តល់ជាជម្រកដល់ជីវចម្រុះយ៉ាងសម្បូរបែបដូចជា ៖ មច្ឆាជាតិ បក្សី ល្មូន ថនិកសត្វ និងរុក្ខជាតិគ្រប់ប្រភេទ ។ ជីវសាស្ត្រចម្រុះក្នុងតំបន់បឹងទន្លេសាបរួមមានៈ មច្ឆាជាតិ ១៧៥ ប្រភេទ ល្មូន ៤២ ប្រភេទ បក្សី ២២៥ ប្រភេទ ថនិកសត្វ ៤៦ ប្រភេទ និងរុក្ខជាតិជាង ២០០ ប្រភេទ ។

ការកាប់ឆ្ការបំផ្លាញព្រៃលិចទឹកដើម្បីអភិវឌ្ឍវិស័យកសិកម្ម កំណើននៃការប្រើប្រាស់ធនធានទឹក ការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតក្នុងវិស័យកសិកម្ម ដោយប្រជាកសិករប្រមាណ ៣០០.០០០ គ្រួសារ អាចធ្វើឱ្យ មានបម្រែបម្រួលលើគុណភាពទឹក និងគុណភាពដី ។ ចាប់តាំងពី ឆ្នាំ ២០០០ មក សកម្មភាពលើវិស័យជលផលមានយ៉ាងសកម្មរួមមានឡូត៍នេសាទចំនួន៣៧ ឡូត៍ សហគមន៍នេសាទចំនួន១៧៨សហគមន៍ ការនេសាទជាលក្ខណៈសិប្បកម្មនិងការនេសាទជាលក្ខណៈគ្រួសារដែលមានប្រមាណ១៣៥.០០០គ្រួសារ។ ការប្រើប្រាស់ ឧបករណ៍នេសាទហួសពីកម្រិតនៃការទ្រទ្រង់របស់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធគ្រប់ប្រភេទ ទោះបីជាលក្ខណៈ ឧស្សាហកម្មក្តី សិប្បកម្មក្តី ឬជាលក្ខណៈគ្រួសារក្តី ដូចជា ការសាងសង់សំណង់របាំងធ្នស់ព្រួល កាត់ព្រែកធំៗ ការប្រើប្រាស់ឧបករណ៍ឆក់ ការបូមបាចពង្រីងស្ទឹង ព្រែក បឹងបួរ... ការកាប់ព្រៃលិចទឹកដើម្បីធ្វើសម្រាស់ ។ល។ សុទ្ធតែបានធ្វើឱ្យមានការប៉ះពាល់ដល់ការធ្វើចរាចររបស់មច្ឆាជាតិ បាត់បង់លំនៅដ្ឋានត្រី បាត់បង់ពូជត្រី... និងធ្វើឱ្យមានផលប៉ះពាល់ដល់ចរន្តទឹក និងការហូរនាំដីល្បាប់ចេញពីតំបន់បឹងទន្លេសាប ។ល។

ក្នុងកំឡុងពេល ៣ ឆ្នាំ កន្លងមកនេះ (ពីឆ្នាំ២០០៩ ដល់ ២០១១) តាមយៈការសិក្សារបស់អាជ្ញាធរទន្លេសាប ឆ្នាំ ២០០៩ ក្នុងចំណោមពូជត្រីចំនួន ១៧៥ ប្រភេទ ដែលមាននៅក្នុងបឹងទន្លេសាប មានការជួបប្រទះជាញឹកញាប់នោះ គឺមាននៅសល់តែប្រមាណ ៦៩ ប្រភេទប៉ុណ្ណោះ ក្នុងនោះ ប្រភេទត្រីដែលគេជួបប្រទះច្រើនជាងគេមាន ៣ ពួក គឺ ពួកត្រីដែលមានស្រកា ពួកត្រីឥតស្រកា និងពួកត្រី ដែល មានធ្មង់ ។ តាមការសិក្សារបស់អាជ្ញាធរទន្លេសាប បាន បង្ហាញថា ទិន្នផលត្រីនៅក្នុងបឹងទន្លេសាប មានការថយចុះយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ និងបានថយចុះយ៉ាងគំហុក ក្នុងឆ្នាំ ២០០៩ និងឆ្នាំ ២០១០ ។

ព្រៃលិចទឹក គឺជារុក្ខជាតិព្រៃឈើក្រាស់ ព្រៃគម្ពោធ ព្រៃរបោះ វល្លិ៍ ស្មៅ និងពពួកវារីរុក្ខជាតិ ដែលដុះជុំវិញបឹងទន្លេសាបទាំងរដូវប្រាំង និងរដូវវស្សា ហើយអាចធន់ទៅនឹងកម្ពស់ទឹកពី ៥ ទៅ ៧ ម៉ែត្រ ។ ព្រៃលិចទឹក មាន ២ប្រភេទ គឺព្រៃលិចទឹកដែលដុះនៅតំបន់ជុំវិញបឹងទន្លេសាប ហើយតំបន់ខ្លះដុះរហូតដល់ ៣០ គ.ម ពីមាត់បឹងទន្លេសាប និងព្រៃរបោះ ឬព្រៃល្បាប់ ដែលដុះនៅតំបន់ទំនាប ជាពិសេសដុះនៅតាមស្ទឹង និងពាមរ៉ៃ ព្រៃដែលដុះនៅជាប់បឹងទន្លេសាបសំបូរទៅដោយដើមឈើធំៗ ដូចជា ដើមរាំងទឹក ផ្ទោល ក្របៅ រទាំង ជាដើម ។ ប្រភេទព្រៃលិចទឹកនៅតំបន់ដីសើមអាចចែកចេញជា ៥ ពួក ក្នុងនោះមាន៖ ដើមឈើ (៤០ ប្រភេទ), ព្រៃគម្ពោធ (៣៨ ប្រភេទ), វល្លិ៍ (៣៣ ប្រភេទ), វារីរុក្ខជាតិ (១៨ ប្រភេទ), ពពួកស្មៅ (២២ ប្រភេទ) សរុប ៖ ព្រៃលិចទឹកនៅតំបន់បឹងទន្លេសាបនាពេលបច្ចុប្បន្នមាន ១៥១ ប្រភេទ ។

ពីឆ្នាំ ២០០២ ដល់ឆ្នាំ ២០០៥ រដ្ឋបាលជលផលបានវាយតម្លៃថា ផ្ទៃក្រឡាព្រៃលិចទឹកនៅតំបន់ជុំវិញបឹងទន្លេសាប បានថយចុះចំនួន ១៣% ពោលគឺ កាលពីឆ្នាំ ២០០២ ព្រៃលិចទឹកមានចំនួន ៧៩១.០០០ ហិកតា តែមកដល់ឆ្នាំ ២០០៥ ព្រៃលិចទឹកនៅសល់ត្រឹមតែ ៦៨៨.១៧០ ហិកតាប៉ុណ្ណោះ ។

ចាប់តាំងពីឆ្នាំ ២០០៥ មក សកម្មភាពបំផ្លិចបំផ្លាញព្រៃលិចទឹក ដោយការដុតឈូសឆាយ ដើម្បីវាតយកដីធ្វើស្រែ ការធ្វើអាជីវកម្មអុសធ្យូង ការប្រើប្រាស់សម្រាប់បំរើការងារសិប្បកម្ម ដូចជា ឆ្អើរត្រី រំងាស់ស្ករ ឡឥដ្ឋ ការប្រើប្រាស់ជាលក្ខណៈគ្រួសារ ការដុតទន្រ្ទានដើម្បីចាប់សត្វ និងការនាំចេញដើមរាំងទឹកទៅលក់ឯបរទេស ការកាប់ព្រៃលិចទឹក សម្រាប់ដាក់សម្រាស់ក្នុងឡូត៍នេសាទ និងក្នុងដែននេសាទសាធារណៈកាន់តែមានទ្រង់ទ្រាយ ធំឡើងៗ និងបានធ្វើឱ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ធនធានព្រៃលិចទឹក ។ ដូច្នេះហើយ តាមសំណើអាជ្ញាធរទន្លេសាប គឺរាជរដ្ឋាភិបាលកម្ពុជាបានកំណត់ដែន ព្រៃលិចទឹកចំនួន ៦៤៧,៤០៦ ហិកតា

(តំបន់៣) ជុំវិញបឹងទន្លេសាប ជាតំបន់ដែលត្រូវការពារដាច់ខាត តាមរយៈអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១១។

## ១.២. ការយល់ដឹងពីអាជ្ញាធរទន្លេសាប

ដោយទទួលស្គាល់ពីសារៈសំខាន់ ពីអត្ថប្រយោជន៍ខាងផ្នែកសេដ្ឋកិច្ច និងបរិស្ថានចំពោះប្រទេសជាតិ និង ប្រជាជនកម្ពុជា បឹងទន្លេសាបត្រូវបានកំណត់ដោយព្រះរាជក្រឹត្យនាខែវិច្ឆិកា ឆ្នាំ ១៩៩៣ ថាជាតំបន់ការពារការប្រើប្រាស់ចម្រុះ (Multiple-Use Protected Area ) ។ បន្ទាប់មកនៅឆ្នាំ ១៩៩៧ អង្គការសហប្រជាជាតិសម្រាប់ការ អប់រំវិទ្យាសាស្ត្រ និងវប្បធម៌ (UNESCO) បានទទួលស្គាល់ពីអត្ថប្រយោជន៍របស់បឹងទន្លេសាប ជាលក្ខណៈជាតិ និងអន្តរជាតិ ហើយបានប្រកាសជាឋបនីយជីវមណ្ឌលបឹងទន្លេសាប ដែលត្រូវបានកំណត់ជាផ្លូវការដោយព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០១ ស្តីពីការបង្កើត និងការគ្រប់គ្រងឋបនីយ ជីវមណ្ឌលបឹងទន្លេសាប ។

រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំបង្កើតឡើងនូវគំនិតផ្តួចផ្តើមបឹងទន្លេសាប (Tonle Sap Initiative) នៅឆ្នាំ ២០០២ ដែលជាទឡ្ហីករណ៍ដ៏ល្អប្រសើរ សម្រាប់បង្ហាញពីការអភិវឌ្ឍន៍នូវយុទ្ធសាស្ត្រគ្រប់វិស័យគ្របដណ្តប់ (Sector wide approach ) ដោយផ្តោតការយកចិត្តទុកដាក់ ទៅលើការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនដែលអាស្រ័យនៅតាមដងទន្លេសាប តាមរយៈយុទ្ធសាស្ត្រគាំពារជនក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចិរភាព ។

ដើម្បីលើកកម្ពស់ និងជំរុញប្រសិទ្ធិភាពដំណើរការការងារគំនិតផ្តួចផ្តើមបឹងទន្លេសាប រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំនូវវេទិកាជាតិ ស្តីពី "កម្រងគម្រោងអភិរក្ស និងអភិវឌ្ឍន៍បឹងទន្លេសាប" ។ កាលពីថ្ងៃទី ០៥-០៦ ខែ មីនា ឆ្នាំ ២០០៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបើកវេទិកាជាតិ **សម្តេចនាយករដ្ឋមន្ត្រី** បានស្នើសុំឱ្យវេទិកា ពិភាក្សាទៅលើលទ្ធភាពបង្កើត "អាជ្ញាធរទន្លេសាប" ឬ "ឧត្តមក្រុមប្រឹក្សាទន្លេសាប" ក្រោមការគ្រប់គ្រងផ្ទាល់របស់រាជរដ្ឋាភិបាល ។

ស្តែងចេញពីលទ្ធផលនៃវេទិកាជាតិស្តីពី កម្រងគម្រោងអភិរក្ស និងអភិវឌ្ឍបឹងទន្លេសាបរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបង្កើត "**អាជ្ញាធរអាងទន្លេសាប**" តាមព្រះរាជក្រឹត្យលេខ នស/រកត/០៩០៧/៤១២ ចុះថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ ២០០៧ ។ ក៏ប៉ុន្តែ ដោយពិនិត្យលើស្ថានភាពជាក់ស្តែង និងការប្រឈមនានារាជរដ្ឋាភិបាល ក៏បានធ្វើ កំណែទម្រង់ជាបន្ទាន់មួយទៅលើរចនាសម្ព័ន្ធគ្រប់គ្រង តួនាទី ភារកិច្ច ក៏ដូចជាដែនសមត្ថកិច្ចរបស់អាជ្ញាធរអាងទន្លេសាប ។ តាមរយៈកំណែទម្រង់នេះ "អាជ្ញាធរទន្លេសាប" ក៏ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ និងបានធ្វើការកែសម្រួលទៅលើមាត្រាមួយចំនួន តាមព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលមាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខនស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ។

អាជ្ញាធរទន្លេសាប គឺជាអង្គភាពថ្នាក់ជាតិមួយ និងជាសេនាធិការផ្ទាល់ឱ្យរាជរដ្ឋាភិបាល ។ បេសកកម្មស្នូលរបស់អាជ្ញាធរទន្លេសាប គឺដើរតួនាទីជាអង្គភាពសិក្សា ស្រាវជ្រាវ តាមដាន និងវាយតម្លៃអំពីសក្តានុពលសេដ្ឋកិច្ច សង្គមកិច្ច និងធនធានធម្មជាតិនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ និងជាអ្នករៀបចំបង្កើត

ឡើងនូវផែនទី បង្ហាញផ្លូវ ទស្សនវិស័យ គោលនយោបាយយុទ្ធសាស្ត្រសម្រាប់ដាក់ជូនសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ពិនិត្យ និងសម្រេចប៉ុន្តែអាជ្ញាធរទន្លេសាបក៏នឹងក្លាយ ខ្លួនជាប្រតិបត្តិករផងដែរនៅពេលទទួលបាននូវបទបញ្ជាផ្ទាល់ពីប្រមុខរាជរដ្ឋាភិបាល ។

ការបង្កើតអាជ្ញាធរទន្លេសាប មានគោលបំណងដូចខាងក្រោម ៖

- ✓ សេនាធិការឱ្យរាជរដ្ឋាភិបាល
- ✓ លើកកម្ពស់កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ដែលជាទិសដៅអាទិភាពដើម្បីលើកកម្ពស់សុខមាលភាព សង្គម និងប្រជាជននៅតំបន់ជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ✓ លើកកម្ពស់កិច្ចការការពារ និងថែរក្សាធនធានធម្មជាតិ និងបរិស្ថាន ដែលជាទិសដៅអាទិភាពដើម្បីធានាដល់គុណភាពធនធានធម្មជាតិ និងបរិស្ថាន
- ✓ ដើរតួនាទីជាអ្នកសម្របសម្រួលរាល់គម្រោងដែលបាន និងកំពុងអនុវត្តនៅតំបន់ជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ។

## ២. ស្ថានភាពអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

អាជ្ញាធរទន្លេសាប មានអគ្គលេខាធិការដ្ឋានមួយ សម្រាប់ដំណើរការការងារប្រចាំថ្ងៃ ហើយដែលមាននាយកដ្ឋានចំនួន 04 និងការិយាល័យចំនួន 14 ក្នុងនោះរួមមាន ៖

| | |
|---|---|
| 1. នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ | មានការិយាល័យចំនួន 04 |
| 2. នាយកដ្ឋានធនធានធម្មជាតិ | មានការិយាល័យចំនួន 04 |
| 3. នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស | មានការិយាល័យចំនួន 03 |
| 4. នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ | មានការិយាល័យចំនួន 03 |

### ២.១. រចនាសម្ព័ន្ធគ្រប់គ្រងអាជ្ញាធរទន្លេសាប

# រចនាសម្ព័ន្ធអាជ្ញាធរទន្លេសាប



### ២.២. នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ

នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ មានតួនាទី និងភារកិច្ចដូចតទៅ:

- ទទួលខុសត្រូវលើសេវាកម្មរដ្ឋបាលទូទៅនិងសម្របសម្រួលការងាររដ្ឋបាលជូនអង្គភាពនៅក្រោមឱវាទ អគ្គលេខាធិការដ្ឋាននៃ **អ.ទ.ស**
- ទទួលខុសត្រូវលើការងារសំណុំលិខិត ឯកសារ លិខិតបទដ្ឋានគតិយុត្តិ ឯកសារសម្ងាត់ ការងារតម្កល់ឯកសារ ពិធីការ សណ្ដាប់ធ្នាប់ និងអនាម័យ
- គ្រប់គ្រងឯកសារ និងក្របខ័ណ្ឌមន្ត្រីរាជការ បុគ្គលិក និងរៀបចំបៀវត្ស ប្រាក់ឧបត្ថម្ភផ្សេងៗ
- គ្រប់គ្រងចលនៈទ្រព្យ អចលនៈទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភ័ណ្ឌរបស់ **អ.ទ.ស**
- រៀបចំផែនការបណ្ដុះបណ្ដាលធនធានមនុស្ស
- រៀបចំគម្រោងផែនការថវិកា សម្ភារៈ និងមធ្យោបាយនានា របស់ **អ.ទ.ស**
- រៀបចំគោលនយោបាយយុទ្ធសាស្ត្រ កម្មវិធី និងផែនការសកម្មភាពការងារ រយៈពេលខ្លី មធ្យម និងវែង សម្រាប់បំរើដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ប្រកបដោយនិរន្តរភាព
- តាមដាន វាយតម្លៃ ប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពការងារ
- សម្របសម្រួល សហការ ជាមួយដៃគូអភិវឌ្ឍន៍នានាដើម្បីកៀរគររកជំនួយ
- រៀបចំកិច្ចប្រជុំ ធ្វើរបាយការណ៍ កំណត់ហេតុ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀត
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **អ.ទ.ស** ប្រគល់ជូន។

### ២.៣. នាយកដ្ឋានធនធានធម្មជាតិ

នាយកដ្ឋានធនធានធម្មជាតិមានតួនាទី និងភារកិច្ចដូចតទៅ:

- សិក្សាស្រាវជ្រាវពីសក្ដានុពលទឹក និងការប្រែប្រួលអាកាសធាតុ ព្រមទាំងកត្តាផ្សេងៗទៀតដែលនាំឱ្យប៉ះពាល់ដល់ធនធានធម្មជាតិ ដែលមាននៅក្នុងបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវពីធនធានមច្ឆាជាតិ ធនធានព្រៃលិចទឹក ធនធានរ៉ែ និងធនធានជីវចម្រុះផ្សេងៗទៀតដែលមាននៅក្នុងបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវពីសក្ដានុពលទឹក-ដី ដែលមាននៅក្នុងបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ពិនិត្យ និងផ្ដល់យោបល់ លើការស្នើសុំប្រើប្រាស់នូវរាល់ធនធានធម្មជាតិ ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **អ.ទ.ស** ប្រគល់ជូន។

### ២.៤. នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស

នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្សមានតួនាទី និងភារកិច្ចដូចតទៅ:

- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្ដល់យោបល់ លើការធ្វើអាជីវកម្មធនធានទឹក-ដី ធនធានមច្ឆាជាតិ ធនធានរ៉ែ ធនធានជីវចម្រុះផ្សេងៗទៀត ដែលមាននៅក្នុងបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្ដល់យោបល់ លើការប្រើប្រាស់រាល់ធនធានធម្មជាតិ ដែលមាននៅក្នុងបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ប្រមូលទិន្នន័យ ព័ត៌មាន វិភាគដើម្បីកំណត់តំបន់អភិរក្សធនធានទឹក ធនធានព្រៃលិចទឹក ធនធានមច្ឆាជាតិ ធនធានរ៉ែ ធនធានជីវចម្រុះផ្សេងៗទៀត ដើម្បីបញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យា

- រៀបចំផែនទី សម្រាប់បម្រើដល់ការគ្រប់គ្រង ការអភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **អ.ទ.ស** ប្រគល់ជូន។

**២.៥. នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ**

នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយមានតួនាទី និងភារកិច្ចដូចតទៅៈ

- ប្រមូលចងក្រង និងសិក្សាស្វែងយល់នូវរាល់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានាដែលមានការពាក់ព័ន្ធ
- ទទួលពាក្យបណ្តឹង និងសម្របសម្រួលនូវរាល់វិវាទនានា ដែលកើតមានឡើងក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ចូលរួមផ្តល់យោបល់ លើការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ
- ផ្សព្វផ្សាយព័ត៌មាន ទាំងវិជ្ជមាន និងអវិជ្ជមានសំដៅបម្រើឱ្យកិច្ចអភិរក្ស និងអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព
- សហការ ជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានាដើម្បីរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **អ.ទ.ស** ប្រគល់ជូន។

## ៣. គោលបំណងនៃផែនការសកម្មភាពការងារ

គោលបំណងផែនការសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប គឺបង្ហាញពីសកម្មភាពអនុវត្តការងាររបស់នាយកដ្ឋាននីមួយៗ ដោយឆ្លើយតបទៅនឹងតួនាទី ភារកិច្ច ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងាររបស់អាជ្ញាធរទន្លេសាប សម្រេចឲ្យបានជោគជ័យប្រកបដោយចិរភាព ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ។

## ៤. លទ្ធផល (Outcome) នៃផែនការសកម្មភាពការងារ

ផែនការសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធិភាពស្របតាមផែនការយុទ្ធសាស្ត្រសម្រាប់អាជ្ញាធរទន្លេសាប ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ។

## ៥. ធាតុចេញ (Output) នៃផែនការសកម្មភាពការងារ

ដើម្បីសម្រេចលទ្ធផល (Outcome) ប្រកបដោយជោគជ័យ គឺតាមរយៈនៃធាតុចេញ (Output) មួយចំនួនរួមមាន ៖

1. នីតិវិធីក្នុងការរៀបចំផែនការសកម្មភាពការងារ
2. សកម្មភាពការងាររបស់នាយកដ្ឋាននីមួយៗ
3. សកម្មភាពការងាររបស់នាយកដ្ឋាននីមួយៗ ត្រូវបានពិនិត្យ និងកែសម្រួល
4. សកម្មភាពការងាររបស់នាយកដ្ឋាននីមួយៗ ត្រូវបានចងក្រង និងប្រមូលផ្តុំជាផែនការសកម្មភាពការងារសម្រាប់អគ្គលេខាធិការដ្ឋាន អ.ទ.ស
5. ផែនការសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន អ.ទ.ស ត្រូវអនុម័ត និងអនុវត្ត

## ៦. សកម្មភាពប្រតិបត្តិការចារ

សកម្មភាពការងារសំខាន់ៗ ដែលបានលើកឡើងដោយនាយកដ្ឋានទាំង 04 គឺដើម្បីសម្រេចបាននូវធាតុចេញ (Output) ដែលត្រូវបានពិភាក្សាយ៉ាងល្អិតល្អន់ និងមានការចូលរួមផ្តល់យោបល់ពីថ្នាក់ដឹកនាំរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ។

**សកម្មភាព ១.** បង្កើនការយកចិត្តទុកដាក់ក្នុងដំណើរការគ្រប់គ្រងរដ្ឋបាល

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- សម្របសម្រួល និងផ្តល់សេវាកម្មក្នុងដំណើរការរដ្ឋបាល
- ពិនិត្យ និងចាត់ចែងលិខិត និងរបៀបរបបការងារក្នុងនាយកដ្ឋាន និងអង្គភាពទាំងមូល
- គ្រប់គ្រង និងចាត់ចែងរៀបចំរាល់បទដ្ឋានគតិយុត្តិ និងឯកសារសម្ងាត់
- ចាត់ចែង និងរៀបចំកិច្ចប្រជុំនានារបស់អង្គភាពទាំងមូល
- គ្រប់គ្រង និងសម្របសម្រួលបណ្តាញទំនាក់ទំនង ទឹក ភ្លើង និងអនាម័យ
- រៀបចំបូកសរុបរបាយការណ៍នាយកដ្ឋាន និងអង្គភាពទាំងមូល

**សកម្មភាព ២.** បង្កើនការយកចិត្តទុកដាក់ក្នុងដំណើរការប្រតិបត្តិគណនេយ្យ និងហិរញ្ញវត្ថុ

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- ពិនិត្យ និងរៀបចំគម្រោងផែនការថវិកាចំណាយប្រចាំឆ្នាំ
- ពិនិត្យ និងគ្រប់គ្រងបញ្ជីចំណូល-ចំណាយ
- ពិនិត្យ និងគ្រប់គ្រងចលនៈ-អចលនៈទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភ័ណ្ឌ
- រៀបចំឯកសារលទ្ធកម្ម
- ផ្គត់ផ្គង់សម្ភារៈ និងបរិក្ខារក្នុងដំណើរការការងារអង្គភាពទាំងមូល
- ចងក្រង រៀបចំរបាយការណ៍

**សកម្មភាព ៣.** បង្កើនការយកចិត្តទុកដាក់ក្នុងដំណើរការគ្រប់គ្រងបុគ្គលិក-មន្ត្រីរាជការ

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- ពិនិត្យ និងរៀបចំគម្រោងផែនការបុគ្គលិកប្រចាំឆ្នាំ
- ពិនិត្យ រៀបចំ និងបូកសរុបបញ្ជីវត្តមានមន្ត្រីរាជការ
- ពិនិត្យ និងវាយតម្លៃសមត្ថភាព ការទទួលខុសត្រូវរបស់មន្ត្រីរាជការ
- រៀបចំឋានន្តរស័ក្តិ តួនាទីជូនមន្ត្រីរាជការ
- បញ្ជ្រាបយេនឌ័រទៅក្នុងអាជ្ញាធរទន្លេសាប
- សម្របសម្រួល និងផ្តល់សេវាកម្មការងារជូនមន្ត្រីរាជការ
- ចងក្រង រៀបចំរបាយការណ៍

**សកម្មភាព ៤.** ប្រមូល ចងក្រង និងរៀបចំផែនការប្រចាំឆ្នាំ

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- ប្រមូល និងចងក្រងឯកសារគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធ
- ពិនិត្យ និងណែនាំជូនដល់នាយកដ្ឋានជំនាញក្នុងការរៀបចំផែនការប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បូកសរុប ចងក្រង និងរៀបចំឯកសារផែនការប្រចាំឆ្នាំរបស់នាយកដ្ឋាន និងអង្គភាពទាំងមូល

- បញ្ជ្រាបផែនការប្រចាំឆ្នាំរបស់អង្គភាពទាំងមូល ចូលក្នុងផែនការប្រចាំឆ្នាំរបស់ក្រសួងធនធានទឹក និងឧតុនិយម
- ចងក្រង និងរៀបចំរបាយការណ៍

**សកម្មភាព ៥.** តាមដាន និងវាយតម្លៃការអនុវត្តផែនការប្រចាំឆ្នាំ

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- ប្រមូល និងចងក្រងរបាយការណ៍ដំណើរការអនុវត្តការងាររបស់នាយកដ្ឋាន និងអង្គភាពទាំងមូល
- ពិនិត្យ និងវិភាគពីវឌ្ឍនភាពការងារក្នុងអនុវត្តផែនការប្រចាំឆ្នាំ
- បូកសរុប និងវាយតម្លៃពីវឌ្ឍនភាពផែនការប្រចាំឆ្នាំរបស់នាយកដ្ឋាន និងអង្គភាពទាំងមូល
- ចងក្រង និងរៀបចំរបាយការណ៍
- វិភាគ ចងក្រងឯកសារគោលនយោបាយ/ឯកសារគោលការណ៍

**សកម្មភាព ៦.** ស្រាវជ្រាវ និងចងក្រងឯកសារគម្រោងពាក់ព័ន្ធនឹងបឹងទន្លេសាប

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- ប្រមូល និងចងក្រងឯកសារគម្រោងកំពុងដំណើរការ បញ្ចប់ និងជាប់កិច្ចសន្យា
- ពិនិត្យ និងចងក្រងគម្រោងកំពុងអនុវត្ត បញ្ចប់ និងការចរចារបស់អាជ្ញាធរទន្លេសាប
- ចងក្រង និងរៀបចំរបាយការណ៍
- វិភាគ ចងក្រងឯកសារគោលនយោបាយ/ឯកសារគោលការណ៍

**សកម្មភាព ៧.** បង្កើនការចូលរួមកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- ប្រមូល និងចងក្រងឯកសារពាក់ព័ន្ធក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ចូលរួមលើកកម្ពស់ការយល់ដឹង និងបញ្ជ្រាបខ្លឹមសារសំខាន់ៗក្នុងកិច្ចការពារធនធានធម្មជាតិជីវចម្រុះបឹងទន្លេសាប
- ទំនាក់ទំនងជាមួយនឹងដៃគូរអភិវឌ្ឍ ម្ចាស់ជំនួយក្នុងការស្វែងរកជំនួយគាំទ្រដល់ដំណើរការងារ និងគម្រោងស្នើសុំរបស់អង្គភាព
- រៀបចំ គម្រោងវិនិយោគសាធារណៈ របស់អាជ្ញាធរទន្លេសាប ដើម្បីបញ្ជ្រាបចូលក្នុងកម្មវិធីវិនិយោគសាធារណៈរបស់ក្រសួងធនធានទឹក និងឧតុនិយម
- ចងក្រង និងរៀបចំរបាយការណ៍
- វិភាគ ចងក្រងឯកសារគោលនយោបាយ/ឯកសារគោលការណ៍

**សកម្មភាព ៨.** បណ្ដុះបណ្ដាល កសាងសមត្ថភាពមន្ត្រីរាជការអាជ្ញាធរទន្លេសាប

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- សម្របសម្រួល និងទំនាក់ទំនងជាមួយនឹងក្រសួង-ស្ថាប័នក្នុងការបញ្ជូនមន្ត្រីអ.ទ.សទទួលការបណ្ដុះបណ្ដាល
- រៀបចំគម្រោងថវិកាស្នើសុំបណ្ដុះបណ្ដាលមន្ត្រីរាជការអាជ្ញាធរទន្លេសាប

– ទំនាក់ទំនងជាមួយនឹងដៃគូរ ម្ចាស់ជំនួយគាំទ្រដល់ការពង្រឹងសមត្ថភាពមន្ត្រីរាជការ
– បញ្ជ្រាបចំណេះដឹងទូទៅដល់មន្ត្រីរាជការ (ការគ្រប់គ្រងរដ្ឋបាល, ផែនការ, ហិរញ្ញវត្ថុ...)
– ចងក្រង និងរៀបចំរបាយការណ៍
– វិភាគ ចងក្រងឯកសារគោលនយោបាយ/ឯកសារគោលការណ៍

**សកម្មភាព ៩.** បច្ចុប្បន្នភាពទិន្នន័យព័ត៌មានផ្ទៃដីដាំដុះដំណាំកសិកម្មជុំវិញបឹងទន្លេសាប

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

– សិក្សា ប្រមូល និងចងក្រងទិន្នន័យព័ត៌មានដែលមានស្រាប់
– ចុះសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យព័ត៌មានតំបន់ពាក់ព័ន្ធជុំវិញបឹងទន្លេសាប
– បញ្ចូលទិន្នន័យទៅក្នុងកុំព្យូទ័រ
– ចងក្រង និងរៀបចំរបាយការណ៍
– វិភាគ ចងក្រងឯកសារគោលនយោបាយ/ឯកសារគោលការណ៍

**សកម្មភាព ១០.** ប្រមូល រៀបចំ និងចងក្រងទិន្នន័យព័ត៌មានអំពីសេដ្ឋកិច្ច សង្គមកិច្ចលើដំណាំកសិកម្មជុំវិញបឹងទន្លេសាប

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

– សិក្សា ប្រមូល និងចងក្រងទិន្នន័យព័ត៌មានដែលមានស្រាប់
– ចុះសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យព័ត៌មានជាមួយនឹងអ្នកពាក់ព័ន្ធលើផលដំណាំសំខាន់ៗ
– បញ្ចូលទិន្នន័យទៅក្នុងកុំព្យូទ័រ
– ចងក្រង និងរៀបចំរបាយការណ៍
– វិភាគ ចងក្រងឯកសារគោលនយោបាយ/ឯកសារគោលការណ៍

**សកម្មភាព ១១.** ចងក្រងសៀវភៅ ស្តីពីប្រភេទស្រូវដាំដុះនៅតំបន់ជុំវិញបឹងទន្លេសាប

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

– សិក្សា ប្រមូល និងចងក្រងឯកសារដែលមានស្រាប់
– សម្ភាសន៍ និងប្រជុំពិភាក្សាជាមួយនឹងអ្នកពាក់ព័ន្ធ អំពីប្រភេទស្រូវដាំដុះសំខាន់ៗ
– រៀបចំផែនទីតំបន់កសិកម្ម និងថតរូបភាពតាមវគ្គលូតលាស់នៃដំណាំស្រូវនីមួយៗ
– ចងក្រង រៀបចំរបាយការណ៍
– ចងក្រង បោះពុម្ពសៀវភៅ

**សកម្មភាព១២.** សិក្សា ចងក្រងពីប្រភពទឹកសំខាន់ៗ សម្រាប់ធ្វើការស្រោចស្រពនៅតំបន់ជុំវិញបឹងទន្លេសាប

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

– សិក្សា ប្រមូល និងចងក្រងទិន្នន័យព័ត៌មានដែលមានស្រាប់
– សម្ភាសន៍ និងប្រជុំពិភាក្សាជាមួយនឹងអ្នកពាក់ព័ន្ធ អំពីប្រភពទឹកសំខាន់ៗសម្រាប់ការស្រោចស្រព។
– ចុះពិនិត្យពីលទ្ធភាពនៃការស្រោចស្រពរបស់កសិករ

- បញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ
- ចងក្រង រៀបចំរបាយការណ៍
- វិភាគ ចងក្រងឯកសារគោលនយោបាយ/ឯកសារគោលការណ៍

**សកម្មភាព ១៣**. សិក្សាស្រាវជ្រាវពីគុណភាពដីកសិកម្មនៅតំបន់ជុំវិញបឹងទន្លេសាប

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- សិក្សា ប្រមូល និងចងក្រងទិន្នន័យព័ត៌មានដែលមានស្រាប់
- ចុះប្រមូលសំណាកដីតាមតំបន់ផលិតស្រូវសំខាន់ៗ
- ធ្វើការពិសោធន៍សំណាកដី
- បញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ
- ចងក្រង រៀបចំរបាយការណ៍
- វិភាគ ចងក្រងឯកសារគោលនយោបាយ/ឯកសារគោលការណ៍

**សកម្មភាព ១៤**. សិក្សាស្រាវជ្រាវពីប្រភេទព្រៃលិចទឹកនៅតំបន់ជុំវិញបឹងទន្លេសាប

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- សិក្សា ប្រមូល និងចងក្រងទិន្នន័យព័ត៌មានដែលមានស្រាប់
- ចុះផ្សព្វផ្សាយសារាចរពីតំបន់ព្រៃលិចទឹក តំបន់ ៣
- ចុះសិក្សា អំពីប្រភេទព្រៃលិចទឹកសំខាន់ៗ និងរៀបចំជាផែនទីព្រៃលិចទឹក ជុំវិញបឹងទន្លេសាប
- បង្កើតមជ្ឈមណ្ឌលថ្នាលបណ្ដុះព្រៃលិចទឹក
- បញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ
- ចងក្រង រៀបចំរបាយការណ៍
- វិភាគ ចងក្រងឯកសារគោលនយោបាយ/ឯកសារគោលការណ៍

**សកម្មភាព ១៥**. សិក្សាស្រាវជ្រាវពីគុណភាពទឹក និងលំហូទឹកនៅតំបន់បឹងទន្លេសាប

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- សិក្សា ប្រមូល និងចងក្រងទិន្នន័យព័ត៌មានដែលមានស្រាប់
- សិក្សារូបសាស្ត្រនៃភាពបត់បែនរបស់ស្ទឹងទាំង១១
- ចុះប្រមូលសំណាក
- ធ្វើការពិសោធន៍សំណាក
- បញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ
- វិភាគ និងគណនាតាមប្រព័ន្ធកុំព្យូទ័រ អំពីលំហូរទឹកនៅតំបន់បឹងទន្លេសាប។
- ចងក្រង រៀបចំរបាយការណ៍
- វិភាគ ចងក្រងឯកសារគោលនយោបាយ/ឯកសារគោលការណ៍

**សកម្មភាព ១៦**. សិក្សាស្រាវជ្រាវពីជីវចម្រុះនៃតំបន់បឹងទន្លេសាប

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- សិក្សា ប្រមូល និងចងក្រងទិន្នន័យព័ត៌មានដែលមានស្រាប់
- ចុះប្រមូលសំណាក និងវិភាគនៅមន្ទីរពិសោធន៍

- សិក្សាអំពីលក្ខណៈជីវសាស្ត្រត្រី ៖ ប្រភេទ លំនៅដ្ឋាន ការបន្តពូជ និងចរាចរត្រី។
- សិក្សាផលស្តុកត្រី និងផលដែលអាចចាប់បាន។
- សិក្សាស្រាវជ្រាវរាវរីរុក្ខជាតិ វារីសត្វទឹក និងសបីសត្វផ្សេង
- បញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ
- ចងក្រង រៀបចំរបាយការណ៍
- វិភាគ ចងក្រងឯកសារគោលនយោបាយ/ឯកសារគោលការណ៍

**សកម្មភាព ១៧.** សិក្សាស្រាវជ្រាវពីលទ្ធភាពស្រោចស្រពនៃប្រព័ន្ធស្ទឹងសំខាន់ៗទាំង ១១ នៅតំបន់ជុំវិញបឹងទន្លេសាប

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- សិក្សា ប្រមូល និងចងក្រងទិន្នន័យព័ត៌មានដែលមានស្រាប់
- ចុះប្រមូលទិន្នន័យតំបន់ពាក់ព័ន្ធជុំវិញស្ទឹងសំខាន់ៗទាំង ១១ នៃបឹងទន្លេសាប
- សិក្សាពីលទ្ធភាពស្រោចស្រព
- បញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ
- ចងក្រង រៀបចំរបាយការណ៍
- វិភាគ ចងក្រងឯកសារគោលនយោបាយ/ឯកសារគោលការណ៍

**សកម្មភាព ១៨.** សិក្សាវាយតម្លៃផលស្តុកត្រីនៅក្នុងបឹងទន្លេសាប

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- សិក្សាបរិមាណ និងប្រភេទត្រីដែលបំលាស់ទីចេញពីបឹងទន្លេសាបចូលទន្លេសាប
- សិក្សាបរិមាណ និងប្រភេទត្រីដែលបំលាស់ទីចេញពីបឹងទន្លេសាបចូលក្នុងអតីតឡូត៍បឹងព្រែក លេខ១២ និងលេខ១៦ខេត្តកណ្តាល
- សិក្សាបរិមាណនិងប្រភេទត្រីដែលបំលាស់ទីចេញពីបឹងទន្លេសាបចូលក្នុងតំបន់ទឹកសាយភាយ នៅក្នុងស្រុកបាធាយ និងស្រុកកង់មាស ខេត្តកំពង់ចាម
- សិក្សាបរិមាណ និងប្រភេទត្រីដែលបំលាស់ទីចេញពីបឹងទន្លេសាបចូលក្នុងស្ទឹងសំខាន់ៗដែលភ្ជាប់ជាមួយបឹងទន្លេសាប
- សិក្សាផលស្តុកនៅក្នុងបឹងទន្លេសាប ( បឹងធំ, បឹងតូច, ព្រៃលិចទឹក, ស្ទឹង, ពាម...)
- តាមដានបរិមាណត្រីនិងប្រភេទត្រីដែលចាប់ដោយឧបករណ៍នេសាទជាលក្ខណៈគ្រួសារនៅក្នុងបឹងទន្លេសាប

**សកម្មភាព ១៩.** សិក្សា ប្រមូល រៀបចំ និងចងក្រងទិន្នន័យព័ត៌មានភូមិសាស្ត្រ

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- ប្រមូលទិន្នន័យព័ត៌មានភូមិសាស្ត្រអំពីតំបន់អភិរក្សនេសាទ
- ប្រមូលទិន្នន័យព័ត៌មានភូមិសាស្ត្រអំពីតំបន់ដែនសហគមន៍នេសាទ
- ប្រមូលទិន្នន័យព័ត៌មានធ្វើបច្ចុប្បន្នភាពការប្រែប្រួលភូមិសាស្ត្រនៃឡូត៍ដាយទាំង ១៥ ជួរ ស្មើនឹង ៦៤ គន្លង នៃរាជធានីភ្នំពេញ និងខេត្តកណ្តាល

- តាមដានចរន្តទឹក ជម្រៅទឹក ស្ថានភាពបាតទន្លេតាមដងទន្លេសាប នៃឡូត៍ដាយនៅក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល
- សិក្សាពីស្ថានភាពបាតបឹងទន្លេសាបនៅក្នុងតំបន់អភិរក្សចំនួន២ (២ស្តួន ខេត្តពង់ធំ, កំពង់-ប្រាក់ក្នុងខេត្តពោធិ៍សាត់)
- រៀបចំផែនទីទីតាំងកែច្នៃផលនេសាទ និងទីកន្លែងពាណិជ្ជកម្មត្រី
- រៀបចំធ្វើផែនទីនៃតំបន់អភិរក្សចាស់ និងថ្មី
- រៀបចំផែនទីឡូត៍ដាយទាំង១៥ ជួរ នៃរាជធានីភ្នំពេញ និងខេត្តកណ្តាល
- រៀបចំផែនទីដើម្បីធ្វើការសិក្សាវាយតម្លៃផលស្តុកនៅក្នុងបឹងទន្លេសាប
- តម្រូវការសម្ភារៈសម្រាប់បម្រើការងារខាងលើ

**សកម្មភាព ២០.** ការធ្វើឲ្យកាន់តែប្រសើរនៅតំបន់អភិរក្សនេសាទ

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- សិក្សាអំពីចំណុចវិជ្ជមាន និងអវិជ្ជមាននៃតំបន់អភិរក្សក្រោយកំណែទម្រង់
- ត្រូវសិក្សាស្វែងយល់ឲ្យបានស៊ីជម្រៅនៅទីតាំងថ្មីៗសម្រាប់បង្កើតតំបន់អភិរក្សថ្មី
- ផ្ទៀងផ្ទាត់និយាមការតំបន់អភិរក្សក្រោយការកែទម្រង់ឡើងវិញ
- វាយតម្លៃប្រសិទ្ធភាពតំបន់អភិរក្សទាំងចាស់ ទាំងថ្មី ដើម្បីធ្វើការកែសម្រួល

**សកម្មភាព ២១.** សហគមន៍ នេសាទ និងវារីវប្បកម្ម

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- ពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពគ្រប់គ្រងរបស់សហគមន៍នេសាទ
- ពិនិត្យ រៀបចំ និងកែសម្រួលសហគមន៍នេសាទឲ្យមានលក្ខណៈល្អប្រសើរ
- ស្រង់ស្ថិតិស្ថានីយ៍ភ្ញាស់ត្រី វារីវប្បកម្មស្រះ និងបែរ
- សិក្សាអំពីកត្តាវិជ្ជមាន និងអវិជ្ជមាននៃវារីវប្បកម្ម និងស្ថានីយ៍ភ្ញាស់ត្រី

**សកម្មភាព ២២.** ការធ្វើអាជីវកម្មកែច្នៃ និងទីផ្សារ

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- សិក្សាចងក្រងទិន្នន័យស្ថិតិ ទីតាំងកែច្នៃ បច្ចេកទេសកែច្នៃ បរិមាណកែច្នៃ និងអ្នកកែច្នៃ
- ស្រង់ស្ថិតិសិប្បករ សិប្បកម្ម និងឧស្សាហកម្ម
- សិក្សាប្រភព ប្រភេទ បរិមាណ និងទំហំត្រីស្រស់យកមកកែច្នៃ
- សិក្សាស្ថិតិផលនេសាទស្រស់ និងកែច្នៃសម្រាប់នាំចេញ
- សិក្សាខ្សែចង្វាក់ផលិតកម្មទីផ្សារត្រីកែច្នៃ

**សកម្មភាព ២៣.** បច្ចុប្បន្នភាពប្រព័ន្ធ website និងប្រព័ន្ធព័ត៌មាន

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- រៀបចំ និងដំណើរការប្រព័ន្ធ website (Domain, Hosting and network internet)
- រៀបចំបណ្ណាល័យសម្រាប់ការសិក្សាស្រាវជ្រាវ
- ប្រមូលចងក្រងព័ត៌មានតាមសារព័ត៌មានក្នុងស្រុក និងក្រៅស្រុក
- រៀបចំប័ណ្ណជូនពរ និងឯកសារពាក់ព័ន្ធសម្រាប់ថ្នាក់ដឹកនាំ និងស្ថាប័ន

– ចងក្រង និងរៀបចំរបាយការណ៍

**សកម្មភាព ២៤.** ផ្សព្វផ្សាយការយល់ដឹងពីការគ្រប់គ្រង អភិវឌ្ឍ និងអភិរក្សតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

– ប្រមូល ចងក្រង និងរៀបចំទស្សនាវដ្ដីអំពីសកម្មភាពរីកចំរើនរបស់អាជ្ញាធរទន្លេសាប
– បង្កើត និងរៀបចំបោះពុម្ពប្រក្រតិទិនប្រចាំឆ្នាំ
– ផ្សព្វផ្សាយកម្រងឯកសារគតិយុត្តិនានារបស់អាជ្ញាធរទន្លេសាបជូនដល់អ្នកពាក់ព័ន្ធ
– សហការជាមួយនឹងដៃគូរពាក់ព័ន្ធ ក្នុងការលើកកម្ពស់ការយល់ដឹងជាសាធារណៈតាមរយៈ សិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលនានាពីការគ្រប់គ្រង អភិវឌ្ឍ និងអភិរក្សតំបន់ទន្លេសាប និង តំបន់ពាក់ព័ន្ធ
– ចងក្រង និងរៀបចំរបាយការណ៍
– ចូលរួម សម្របសម្រួលក្នុងការប្រមូល ចងក្រងឯកសារគោលនយោបាយ/ឯកសារគោល ការណ៍

**សកម្មភាព ២៥.** សិក្សាស្រាវជ្រាវ និងចងក្រងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការគ្រប់គ្រង អភិវឌ្ឍ និង អភិរក្សតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

– ប្រមូល និងចងក្រងឯកសារបទដ្ឋានគតិយុត្តិនានាដែលមានស្រាប់
– ប្រមូល និងចងក្រងឯកសារបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធនឹងកិច្ចការពារតំបន់ទន្លេសាប
– ចងក្រង និងរៀបចំរបាយការណ៍

**សកម្មភាព ២៦.** រៀបចំ និងពង្រឹងសមត្ថភាពមន្ត្រីជំនាញក្នុងការដោះស្រាយវិវាទក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

– វាយតម្លៃកម្រិតសមត្ថភាពរបស់មន្ត្រីជំនាញពាក់ព័ន្ធនឹងការយល់ដឹងពីការសម្របសម្រួលវិវាទ ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាប និងពាក់ព័ន្ធ
– ប្រមូល និងចងក្រងឯកសារពាក់ព័ន្ធ និងវិវាទ
– បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីក្នុងការសម្របសម្រួលវិវាទ
– ចងក្រង និងរៀបចំរបាយការណ៍

**សកម្មភាព ២៧.** រៀបចំ និងពង្រឹងសមត្ថភាពការយល់ដឹងពីការសម្របសម្រួលវិវាទ ដល់សហគមន៍ពាក់ព័ន្ធ នឹងកិច្ចការពារធនធានធម្មជាតិ ជីវចម្រុះបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

– ប្រមូល និងចងក្រងសហគមន៍ពាក់ព័ន្ធនឹងតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
– វាយតម្លៃកម្រឹតសមត្ថភាពជំនាញសហគមន៍ពាក់ព័ន្ធ
– បណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទពាក់ព័ន្ធក្នុងការសម្រប សម្រួលដោះស្រាយវិវាទ
– ចងក្រង និងរៀបចំរបាយការណ៍

**សកម្មភាព ២៨.** បញ្ជ្រាបការយល់ដឹងជាសាធារណៈដល់ប្រជាជនក្នុងកិច្ចការពារធនធានធម្មជាតិ ជីវចម្រុះ បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- សិក្សាស្រាវជ្រាវ និងចងក្រងឯកសារពាក់ព័ន្ធនឹងកិច្ចការពារធនធានធម្មជាតិ ជីវចម្រុះបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ផ្សព្វផ្សាយការយល់ដឹងជាសាធារណៈដល់ប្រជាជនក្នុងការចូលរួមការពារធនធានធម្មជាតិ ជីវចម្រុះបឹងទន្លេសាប
- ចងក្រង និងរៀបចំរបាយការណ៍

**សកម្មភាព ២៩.** សិក្សាស្វែងយល់អំពីការអនុវត្តច្បាប់ និងការដោះស្រាយវិវាទនៅមូលដ្ឋានទាក់ទងនឹងការគ្រប់គ្រងធនធាន និងបរិស្ថាន តំបន់បឹងទន្លេសាប

ជំហានអនុវត្តសំខាន់ៗរបស់សកម្មភាពការងារ (Milestones) :

- សិក្សាស្វែងយល់អំពីការអនុវត្តច្បាប់ និងការដោះស្រាយវិវាទនៅមូលដ្ឋានទាក់ទងនឹងការគ្រប់គ្រងធនធាន និងបរិស្ថាន តំបន់បឹងទន្លេសាប
- សម្របសម្រួលជាមួយ អង្គការ ស្ថាប័នពាក់ព័ន្ធ រៀបចំ និងពង្រឹងបណ្តាញ និងប្រព័ន្ធដោះស្រាយវិវាទក្នុងវិស័យគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិ និងតំបន់បឹងទន្លសាប និងតំបន់ពាក់ព័ន្ធ
- ស្រាវជ្រាវ និងរៀបចំលិខិតគតិយុត្តិសម្រាប់ពង្រឹងអភិបាលកិច្ច ដោយមានការចូលរួមពីអ្នកច្បាប់ពាក់ព័ន្ធនានា។
- សម្របសម្រួលបង្កើតជនបង្គោលសម្រាប់ការតាមដានវិវាទនៅថ្នាក់មូលដ្ឋាន និងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ និងតម្រូវការវគ្គបណ្តុះបណ្តាលសម្រាប់ធ្វើអភិបាលកិច្ចការគ្រប់គ្រងសហគមន៍

## ៧. តាមដានត្រួតពិនិត្យ និងវាយតំលៃ

ដំណើរការនៃការតាមដានត្រួតពិនិត្យ ដែលមានលក្ខណៈប្រសើរឆ្ពោះទៅរកគោលបំណងនៃផែនការសកម្មភាពការងារ និងផលប៉ះពាល់នៃការអនុវត្តការងារនេះ ត្រូវបានវាយតម្លៃទៅលើសូចនាករ ដែលបានកំណត់នៅក្នុងការរៀបចំ និងក្របខណ្ឌនៃការតាមដានត្រួតពិនិត្យនៅក្នុង**តារាងសូចនាករ** ហើយរបាយការណ៍ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំជារៀងរាល់ត្រីមាស (3 ខែ) សម្រាប់ដាក់ជូនដល់ថ្នាក់ដឹកនាំ នៃអាជ្ញាធរទន្លេសាប និងអ្នកពាក់ព័ន្ធ ។ របាយការណ៍តាមដានត្រួតពិនិត្យ និងវាយតំលៃទៅលើសកម្មភាពអនុវត្តការងាររបស់នាយកដ្ឋាននីមួយៗ ត្រូវបានរៀបចំឡើងដោយយោងទៅតាមលក្ខខណ្ឌតម្រូវរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ។ មធ្យោបាយនៃការបញ្ជាក់អះអាង (Means of the verification) សម្រាប់សូចនាករទាំងនោះ បានកំណត់នៅក្នុងការការរៀបចំ និងក្របខណ្ឌនៃការតាមដានត្រួតពិនិត្យ ។ សេចក្តីលំអិតបន្ថែមទៀតនឹងត្រូវបានផ្តល់ជូនក្នុងផែនការប្រចាំឆ្នាំជាបន្តបន្ទាប់។

ក្រៅពីការត្រួតពិនិត្យជាប្រចាំ នឹងមានការសិក្សាវាយតម្លៃនៅពាក់កណ្តាលអាណត្តិ តាមរយៈការវាយតម្លៃបឋម នៃផលប៉ះពាល់លើដំណើរការចំណាយ និងបម្រែបម្រួលស្ថានភាពខាងក្រៅ ដែលនឹងត្រូវបានធ្វើការវាយតម្លៃ និងកំណត់តាមការដែលអាចអនុវត្តបាន ។

# សូចនាករ នៃក្របខ័ណ្ឌការរៀបចំ និងការត្រួតពិនិត្យ
# សម្រាប់ផែនការសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប

| សេក្តីសង្ខេបនៃការរៀបចំ | ទិសដៅអនុវត្ត និងសូចនាករ | ប្រភពទិន្នន័យ និងយន្តការរបាយការណ៍ | ការសន្មត និងហានិភ័យ |
|---|---|---|---|
| **គោលបំណងនៃផែនការសកម្មភាពការងារ**<br>បង្ហាញពីសកម្មភាពអនុវត្តការងារ របស់នាយកដ្ឋាននីមួយៗដោយឆ្លើយតបទៅនឹងតួនាទីភារកិច្ចដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងាររបស់អាជ្ញាធរទន្លេសាប សម្រេចឲ្យបានជោគជ័យប្រកបដោយចិរភាព ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប និង តំបន់ពាក់ព័ន្ធ | – ការរៀបចំផែនការយុទ្ធសាស្ត្រ (២០១៦-២០២០) ត្រូវបានបញ្ចប់ និងអនុម័ត<br>– បច្ចុប្បន្នភាពផែនការសកម្មភាពការងារ (២០១៥-២០១៧) សម្រាប់គាំទ្រដល់ដំណើរ ការអនុវត្តផែនការយុទ្ធសាស្ត្រ<br>– ការអនុវត្តផែនការយុទ្ធសាស្ត្រ (២០១៦-២០២០) ប្រកបដោយជោគជ័យ និងប្រសិទ្ធភាព | - របាយការណ៍ស្នើសុំគោលការណ៍ឯកភាពអនុវត្តផែនការសកម្មភាពការងារ (២០១៤-២០២០)<br>- របាយការណ៍អនុវត្តសកម្មភាពនីមួយៗរបស់នាយកដ្ឋាន<br>- ការតាមដានត្រួតពិនិត្យ និងវាយតំលៃពីប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពការងារ | **ការសន្មត**<br>- មានការគាំទ្រពីអ្នកពាក់ព័ន្ធការអនុវត្ត ផែនការសកម្មភាពការងារ<br>- ចូលរួមលើកកម្ពស់គោលនយោបាយរាជរដ្ឋាភិបាល តាមរយៈការគាំទ្ររៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប<br>**ហានិភ័យ**<br>- កញ្ចប់ថវិការដ្ឋ មានកំណត់ក្នុងការគាំទ្រដំណើរការអនុវត្តសកម្មភាពការងារ<br>- ពុំមានថវិកាពីដៃគូអភិវឌ្ឍ ម្ចាស់ជំនួយ ដើម្បីគាំទ្រអនុវត្តសកម្មភាព ការងារទាំងអស់នេះ |
